**សេចក្តីព្រាង**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ................ អនក្រ**

# អនុក្រឹត្យ
# ស្តីពី
# ការកំណត់តំបន់ធនធានរ៉ែ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## សម្រេច

**មាត្រា ១ .-**

តំបន់ធនធានរ៉ែ គឺជាតំបន់ដែលជម្រករ៉ែឬសន្ទស្សន៍រ៉ែត្រូវបានសិក្សាស្រាវជ្រាវរកឃើញ ឬជាតំបន់ដែលរចនាសម្ព័ន្ធភូគព្ភសាស្ត្របានបង្ហាញអំពីលទ្ធភាពនៃវត្តមានធនធានរ៉ែ ។

តំបន់ធនធានរ៉ែ ត្រូវបានកំណត់ដើម្បីរក្សាទុកជាតំបន់ការពារ និងតំបន់បម្រុងទុក ដូចមានក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះសម្រាប់បម្រើដល់ប្រតិបត្តិការធនធានរ៉ែ ។

**មាត្រា ២ .-**

តំបន់ការពារ គឺជាតំបន់ដែលសន្ទស្សន៍រ៉ែត្រូវបានសិក្សាស្រាវជ្រាវរកឃើញ ឬជាតំបន់ដែលរចនាសម្ព័ន្ធភូគព្ភសាស្ត្របង្ហាញអំពីលទ្ធភាពនៃវត្តមានធនធានរ៉ែ ។

តំបន់បម្រុងទុក គឺជាតំបន់ដែលជម្រករ៉ែត្រូវបានសិក្សាស្រាវជ្រាវរកឃើញហើយព័ត៌មាន និងទិន្នន័យភូគព្ភសាស្ត្រអំពីសក្តានុពលធនធានរ៉ែត្រូវបានកំណត់ ។

**មាត្រា ៣ .-**

រាល់សំណើគំរោងអភិវឌ្ឍន៍ និងការសាងសង់ទីកន្លែងសក្ការៈបូជា បូជនីយដ្ឋាន ទីកន្លែងបញ្ចុះសព ឬសំណង់នានា ក្នុងតំបន់ការពារត្រូវសុំយោបល់ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលជាមុនសិន។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវសិក្សា និងវាយតម្លៃលើទីតាំងដែលបានស្នើសុំខាងលើ រួចត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរអំពីការយល់ព្រម ឬបដិសេធចំពោះគំរោងការអភិវឌ្ឍន៍នោះ ដោយបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃដែលទទួលបានពាក្យស្នើសុំគ្រប់គ្រាន់ និងត្រឹមត្រូវ ។

**មាត្រា ៤ .-**

ការអភិវឌ្ឍន៍ និងការសាងសង់ទីកន្លែងសក្ការៈបូជា បូជនីយដ្ឋាន ទីកន្លែងបញ្ចុះសព ឬសំណង់នានា នៅក្នុងតំបន់បម្រុងទុកត្រូវហាមឃាត់ជាដាច់ខាត។

តំបន់បម្រុងទុក ត្រូវបានរក្សាទុកសម្រាប់ធ្វើការស្វែងរុករក ឬធ្វើអាជីវកម្មធនធានរ៉ែតែប៉ុណ្ណោះ ។

**មាត្រា ៥ .-**

គ្មានរូបវ័ន្តបុគ្គល ឬនីតិបុគ្គលណាមួយអាចកាន់កាប់តំបន់ធនធានរ៉ែដែលជាដីសាធារណៈរបស់រដ្ឋក្រៅពីសម្បទានិកដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានចុះកិច្ចព្រមព្រៀងជាមួយ ឬបានផ្តល់អាជ្ញាប័ណ្ណធនធានរ៉ែ សម្រាប់ស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែបានឡើយ ។

**មាត្រា ៦ .-**

តំបន់ធនធានរ៉ែអាចត្រូវបន្ថែម ឬលុបចោលពីក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ក្នុងករណីដែលបានរកឃើញសន្ទស្សន៍រ៉ែ ឬជម្រករ៉ែថ្មីៗថែមទៀត ឬក្នុងករណីដែលសន្ទស្សន៍រ៉ែ ឬជម្រករ៉ែដែលបានរកឃើញកន្លងមកមិនមានតម្លៃពាណិជ្ជកម្ម ។

**មាត្រា ៧ .-**

ប្រសិនបើធនធានរ៉ែត្រូវបានរកឃើញនៅក្នុងតំបន់ថ្មី ដែលពុំមានចែងនៅក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ហើយជាដីកម្មសិទ្ធិស្របច្បាប់របស់ឯកជន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវធ្វើការចរចាជាមួយម្ចាស់ដីកម្មសិទ្ធិនោះដោយផ្តល់សំណងសមរម្យ និងយុត្តិធម៌ ។ សំណង គឺជាបន្ទុករបស់ប្រតិបត្តិករដែលធ្វើប្រតិបត្តិការធនធានរ៉ែនៅក្នុងតំបន់នោះ។

ក្នុងករណីដែលតំបន់ធនធានរ៉ែរកឃើញថ្មីគឺជាតំបន់ព្រៃឈើ ព្រៃសម្បទាន ព្រៃសហគមន៍ ព្រៃជំនឿសាសនា ដីសម្បទានសង្គមកិច្ច ដីអភិវឌ្ឍន៍ តំបន់ការពារធនធានធម្មជាតិ និងតំបន់ផ្សេងៗទៀត ដែលត្រូវការការពារដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវធ្វើការសម្របសម្រួលព្រមព្រៀងជាមួយស្ថាប័ន

ពាក់ព័ន្ធជាមុនសិនមុននឹងប្រកាសជាតំបន់ការពារ ឬជាតំបន់បម្រុងទុក ។

ក្នុងករណីស្ថាប័នពាក់ព័ន្ធទាំងអស់មិនឯកភាពគ្នាទេនោះ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវធ្វើសំណើជូនប្រមុខរាជរដ្ឋាភិបាលដើម្បីពិនិត្យសម្រេច។

**មាត្រា ៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**<u>ចម្លងជូន</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ